# សារពីសហប្រធានគណៈកម្មការទំនាក់ទំនងនិងសារព័ត៌មាន

*ស្វាគមន៍មកកាន់មហោស្រពសិល្បៈយុវវ័យខ្មែរ ២០១០!*



*តាំងនាមឲ្យគណៈកម្មការទំនាក់ទំនងនិងសារព័ត៌មាន នាងខ្ញុំមានសេចក្តីរំភើប និងសោមនស្សជាខ្លាំងដែលបានរួមចំណែកប្រារព្ធធ្វើមហោស្រពសិល្បៈដ៏ធំនេះ ។ ហើយនេះក៏ជាលើកទី១ របស់នាងខ្ញុំផ្ទាល់ដែរ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍ដ៏មហោឡារិកនេះ ។*

*ថ្វីបើសាវតារនាងខ្ញុំមានជាប់ពាក់ព័ន្ធនិងសិល្បៈជាងការផ្សព្វផ្សាយ នាងខ្ញុំនៅតែខិតខំពុះពារឲ្យអស់ពីសមត្ថភាព ដើម្បីដឹកនាំគណៈកម្មការឲ្យធ្វើការប្រកបដោយភាពរលូន ស៊ីសង្វាក់ និងយោគយល់គ្នា ។ ការងារ ទាំងអស់នេះអាចសម្រេចទៅបាន ក៏ដោយសារមានការជួយជ្រោមជ្រែងពីសំណាក់សមាជិកក្រុមរបស់នាងខ្ញុំផ្ទាល់គឺ* **ក្រុមកូនខ្មែរកូនខ្មែរ** *និងកិច្ចសហការណ៍ដ៏ស្អិតរមួតជាមួយបុគ្គលិករបស់* **សិល្បៈខ្មែរអមតៈ** *ដែលជាស្ថាប័នផ្តួចផ្តើមឲ្យមានព្រឹត្តិការណ៍នេះឡើង ។*

*នាងខ្ញុំសង្ឃឹមថា ការរៀបចំរបស់គណៈកម្មការរបស់នាងខ្ញុំ នឹងអាចជួយព្រឹត្តិការណ៍នេះមានការ ទទួលស្គាល់ និង កោតសសើរទាំងមុនពេល កំឡុងពេល និងក្រោយពេលដំណើរការ ។ ហើយការងាររបស់នាងខ្ញុំនឹងជួយឲ្យ សិល្បៈខ្មែរទាំងបុរាណនិងសម័យមានការរីកសាយភាយពេញផ្ទៃប្រទេសក៏ដូចជាទូទាំងពិភពលោក ។*

*ចុងក្រោយនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សិល្បៈខ្មែរអមតៈដែលផ្តើមគំនិត បង្កើតវេទិកាសិល្បៈនេះឡើង ដល់អជ្ញាធរដែនដីដែលអនុញ្ញាតឲ្យភារកិច្ចរបស់គណៈកម្មការនាងខ្ញុំ មានភាពងាយស្រួលដល់ គណៈកម្មការផ្សេងទៀតដែលជួយសម្របសម្រួលការខ្វះខាត ដល់អ្នកព័ត៌មាន គ្រប់រូបដែលជួយផ្សព្វផ្សាយនិងគាំទ្រ ក៏ដូចជាអង្គភាពពាក់ព័ន្ធផ្សេងៗទៀតដែលរួមវិភាគទានដល់មហោស្រពនេះ ។ នាងខ្ញុំរំពឹងយ៉ាងមុតមាំថា ប្រិយមិត្តអ្នកអាន ក៏នឹងជួយប្រាប់បន្តពីអ្វីដែលយើងខ្ញុំកំពុងសម្រេច ដល់មិត្តភក្តិនិងអ្នកឯទៀតឲ្យបានចូលរួមដោយផ្ទាល់និង ទស្សនាបានកុះករផង ។*



ខ្ញុំបាទមានការរីករាយយ៉ាងខ្លាំងក្នុងការចូលរួមរៀបចំព្រឹត្តិការណ៍ធំនេះ ។ មហោស្រពសិល្បៈយុវវ័យខ្មែរ ជាសក្ខីភាពដែលបង្ហាញពីការធ្វើការជាក្រុម ជាសម្ពន្ធ និងកិច្ចសហការរបស់សហគមន៍សិល្បៈ ។ មហោស្រពនេះផ្តល់ ឱកាសដល់ សិល្បករចូលរួមបង្ហាញស្នាដៃរបស់ពួកគេតាមរយៈការសម្តែង និងផ្លាស់ប្តូរបទពិសោធន៍ផ្នែកទម្រង់ សិល្បៈរវាងគ្នានិងគ្នារបស់សិល្បករ ។ អនុលោមតាមគំរូនេះ ចំណេះដឹងរបស់សិល្បករបានកើនឡើងមួយកម្រិតថែមទៀត ។ អ្វីដែលពួក យើងខ្ញុំបានខិតខំចំណាយពេលវេលានិងកម្លាំងដើម្បីរៀបចំ យើងខ្ញុំសង្ឃឹមថាវានឹងក្លាយជាព្រឹត្តការណ៍ដ៏អស្ចារ្យ, សប្បាយរីករាយសម្រាប់សិល្បករចូលរួម (គ្រូបាធ្យាយនិងសិស្សសិល្បៈ) ។ យើងខ្ញុំសង្ឃឹមយ៉ាង មុតមាំថា **មហាស្រពសិល្បៈយុទវ័យខ្មែរ** នឹងក្លាយជាគំរូមួយសម្រាប់ការរៀបចំព្រឹត្តិការណ៍ផ្សេងៗទៀត មិនចំពោះតែ វិស័យសិល្បៈប៉ុណ្ណោះទេ លើសពីនោះទៅទៀត មហោស្រពឆ្នាំនេះក៏មានការខុសប្លែកពីឆ្នាំមុនពីព្រោះពួកយើងមាន អ្នករៀបចំ ដែលភាគច្រើនសុទ្ធសឹងតែជាយុវវ័យវិសាទរ ដែលជាធនធានដ៏មានតម្លៃក្នុងការអភិ វឌ្ឍសង្គមជាតិ ។

ជាចុងក្រោយខ្ញុំសូមជូនពរដល់ ក្រុមសិល្បៈ សមាគម អង្គការ និងក្លិបដែលចូលរួមបានទទួលបទពិសោធន៍ ដែលមិនអាចបំភ្លេចបានពីមហោស្រពសិល្បៈយុវវ័យខ្មែរឆ្នាំ២០១០ ។

សូមទទួលយកនូវការរាប់អានដ៏ជ្រាលជ្រៅអំពីយើងទាំងពីរនាក់ ៕

កញ្ញា ទិត្យ កន្និដ្ឋា

លោក ចាប វិធូរ